ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
ក្រុមអ្នកនាំពាក្យ
លេខ: ០៣៨ គ.ជ.ប

ថ្ងៃ សុក្រ ៤កើត១៥ ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែសីហា ឆ្នាំ២០២៤

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## ការផ្សព្វផ្សាយអំពីសភាពការណ៍ទូទៅមុនចាប់ផ្តើមដំណើរការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០២៤

នាព្រឹកថ្ងៃសុក្រ ទី២៣ ខែសីហា ឆ្នាំ២០២៤ វេលាម៉ោង ១០:០០ នៅសាលសន្និសីទរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) មានកិច្ចប្រជុំជាមួយភាគីពាក់ព័ន្ធនឹងការបោះឆ្នោត ក្រោមអធិបតីភាពរបស់ **ឯកឧត្តម ឌឹម សុវណ្ណារុំ** សមាជិក គ.ជ.ប និងជាប្រធានក្រុមប្រតិកម្មព័ត៌មាន គ.ជ.ប និងជាប្រធានដឹកនាំកិច្ចប្រជុំដើម្បីផ្សព្វផ្សាយអំពីការងារសន្តិសុខ សម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ការចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយ និងសភាពការណ៍ទូទៅមុនចាប់ផ្តើមដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០២៤។

**ឯកឧត្តម ឌឹម សុវណ្ណារុំ** បានមានប្រសាសន៍ថា **ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតតាមឃុំ សង្កាត់ នឹងចាប់ផ្តើមពីថ្ងៃទី១ ដល់ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២៤ ខាងមុខនេះ** និងដើម្បីឱ្យដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ប្រព្រឹត្តទៅក្នុងបរិយាកាសសន្តិសុខល្អប្រសើរ ធានាបាននូវសណ្តាប់ធ្នាប់ របៀបរៀបរយ និងសុវត្ថិភាព គ្មានការភិតភ័យ ឬការបំភិតបំភ័យ ដូចជា គ្មានការគំរាមកំហែង និងគ្មានអំពើហិង្សា ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត កាលពីថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២១ បានដាក់ចេញនូវផែនការអន្តរស្ថាប័ន ស្តីពីកិច្ចការពារការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ និងការបោះឆ្នោត ថ្នាក់ជាតិ-ថ្នាក់ក្រោមជាតិ ចាប់ពីឆ្នាំ២០២២ ដល់ឆ្នាំ២០២៨។ **ឯកឧត្តម** បន្តថា គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍សម្រាប់ការបោះឆ្នោត និង គ.ជ.ប បានបន្តកិច្ចសហការយ៉ាងជិតស្និទ្ធ ដើម្បីធានាការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ ក្នុងដំណើរការនៃការពិនិត្យ



អគារ គ.ជ.ប៖ វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ ៖ 012 959 666 / 012 636 007 / 012 855 018
NEC Building : St. Ratsaphea, Sangkat Tonle Basac, Khan Chamkar Mon, Phnom Penh, Kingdom of Cambodia អ៊ីម៉ែល ៖ info@nec.gov.kh

បញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត និងការផ្តល់សុពលភាពលើបញ្ជីបោះឆ្នោត ឆ្នាំ២០២៤ ដោយបានចាត់វិធានសំខាន់ៗ មានដូចជា៖

១. មុខសញ្ញាសំខាន់ៗដែលត្រូវការពារ

២. គោលដៅសំខាន់ៗដែលត្រូវការពារ

៣. អំពីការរៀបចំយន្តការ/រចនាសម្ព័ន្ធសន្តិសុខបោះឆ្នោតនៅរាជធានី ខេត្ត

**ឯកឧត្តម ឌឹម សុវណ្ណារុំ** បានមានប្រសាសន៍បន្តទៀតថា គណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ដែលមានស្រាប់ ត្រូវបានកំណត់ និងប្រើប្រាស់ជាយន្តការរចនាសម្ព័ន្ធសន្តិសុខបោះឆ្នោតរាជធានី ខេត្ត ហៅថា **គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍រាជធានី ខេត្ត សម្រាប់ការបោះឆ្នោត** ត្រូវបំពេញមុខងារតាមឋានៈ តួនាទី និងការទទួលខុសត្រូវក្នុងដែនសមត្ថកិច្ចរាជធានី ខេត្តរៀងៗខ្លួន ដែលមានស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ធ្វើជាសេនាធិការ ត្រូវគ្រប់គ្រង ដឹកនាំ និងបញ្ជាគ្រប់យន្តការ រចនាសម្ព័ន្ធសន្តិសុខ និងមន្ត្រីអនុវត្តច្បាប់នៅក្រោមឱវាទ ដោយសហការជាមួយ គ.ជ.ប ឬ/និង លធ.ឧប ត្រួតពិនិត្យការរៀបចំកម្លាំងនគរបាលការពារ និងកម្លាំងកងរាជអាវុធហត្ថតាមផែនការ និងសេចក្តីណែនាំផ្សេងៗដែលបានកំណត់។ កម្លាំងនគរបាលនៃស្នងការដ្ឋាននគរបាលរាជធានី ខេត្ត អធិការដ្ឋាននគរបាលក្រុង ស្រុក ខណ្ឌ និងប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ ឬ/និង កម្លាំងកងរាជអាវុធហត្ថនៃបញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានី ខេត្ត និងមូលដ្ឋានកងរាជអាវុធហត្ថក្រុង ស្រុក ខណ្ឌ ត្រូវបានរៀបចំជាភ្នាក់ងារសន្តិសុខបោះឆ្នោត តាមសំណូមពរចាំបាច់របស់ គ.ជ.ប ឬ/និង លធ.ឧប។

អំពីការចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយ **ឯកឧត្តម ឌឹម សុវណ្ណារុំ** បានមានប្រសាសន៍ថា គណបក្សនយោបាយទាំងអស់ដែលបានចុះបញ្ជីត្រឹមត្រូវស្របតាមច្បាប់ ស្តីពីគណបក្ស-នយោបាយ នៅក្រសួងមហាផ្ទៃ មានសិទ្ធិចាត់តាំងភ្នាក់ងាររបស់ខ្លួនមួយចំនួនតាមការចាំបាច់របស់គណបក្ស ដើម្បីសង្កេតមើលការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត នៅតាមសាលាឃុំ សង្កាត់ ឬតាមការិយាល័យចុះឈ្មោះបោះឆ្នោតក្នុងឃុំ សង្កាត់ ដែលកំណត់ដោយ គ.ជ.ប។ គណបក្សនយោបាយដែលមានបំណងចាត់តាំងភ្នាក់ងាររបស់ខ្លួន ដើម្បីសង្កេតមើលការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ត្រូវដាក់ពាក្យសុំចុះឈ្មោះភ្នាក់ងាររបស់ខ្លួនទៅក្រុមប្រឹក្សាឃុំ សង្កាត់ **៧ (ប្រាំពីរ) ថ្ងៃ** មុនថ្ងៃចាប់ផ្តើមដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត រហូតដល់ **១០ (ដប់) ថ្ងៃ** មុនថ្ងៃបញ្ចប់ដំណើរការនេះ។ ដូចនេះ ផ្អែកតាមប្រតិទិននៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០២៤ កាលបរិច្ឆេទនៃការចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយ ចាប់ផ្តើមពី**ថ្ងៃទី២៥ ខែសីហា ដល់ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤**។



អគារ គ.ជ.ប៖ វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ ៖ 012 959 666 / 012 636 007 / 012 855 018
NEC Building : St. Ratsaphea, Sangkat Tonle Basac, Khan Chamkar Mon, Phnom Penh, Kingdom of Cambodia អ៊ីម៉ែល ៖ info@nec.gov.kh

គណបក្សនយោបាយត្រូវដាក់ពាក្យសុំចុះឈ្មោះភ្នាក់ងារ តាមទម្រង់បែបបទលេខ ១០០៧ ដែលផ្ដល់ជូនដោយ គ.ជ.ប ដោយឥតគិតថ្លៃ ឬអាចទាញយកពីគេហទំព័ររបស់ គ.ជ.ប (www.nec.gov.kh)។

**ឯកឧត្តម ឌឹម សុវណ្ណារុំ** បានបញ្ជាក់ថា បន្ទាប់ពីក្រុមប្រឹក្សាឃុំ សង្កាត់ សម្រេចអនុញ្ញាតលើពាក្យសុំចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយរួចហើយ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវផ្ដល់បណ្ណសម្គាល់ខ្លួនជូនភ្នាក់ងារគណបក្សនយោបាយតែ ២ (ពីរ) បណ្ណប៉ុណ្ណោះ គឺ ១ (មួយ) បណ្ណសម្រាប់ភ្នាក់ងារពេញសិទ្ធិ និង ១ (មួយ) បណ្ណ សម្រាប់ភ្នាក់ងារបម្រុង។ បណ្ណសម្គាល់ភ្នាក់ងារគណបក្សនយោបាយ មានសុពលភាពប្រើប្រាស់បានតែក្នុងដំណាក់កាលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតតែប៉ុណ្ណោះ។ ភ្នាក់ងារពេញសិទ្ធិ ១ (មួយ) រូប នៃគណបក្សនយោបាយនីមួយៗ ត្រូវបានអនុញ្ញាតឱ្យចូលក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត។ ភ្នាក់ងារបម្រុង ១ (មួយ) រូប ត្រូវបានអនុញ្ញាតឱ្យចាំនៅក្រៅការិយាល័យចុះឈ្មោះបោះឆ្នោត ដើម្បីជំនួសភ្នាក់ងារពេញសិទ្ធិក្នុងករណីត្រូវផ្លាស់ប្ដូរ ឬអវត្តមាន។ **ឯកឧត្តម** បានបញ្ជាក់បន្ថែម អំពីលក្ខខណ្ឌសុំចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយ គឺត្រូវ៖

- មានឈ្មោះក្នុងបញ្ជីបោះឆ្នោតក្នុងឃុំ សង្កាត់ ដែលភ្នាក់ងារនោះត្រូវសង្កេតមើលការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត
- មានសមត្ថភាពអាចបំពេញការងារបាន តាមការធានារបស់គណបក្សនយោបាយ
- បានទទួលការហ្វឹកហ្វឺនជាភ្នាក់ងារគណបក្សនយោបាយ តាមការធានារបស់គណបក្ស-នយោបាយសាមី
- មានឈ្មោះក្នុងបញ្ជីភ្នាក់ងារគណបក្សនយោបាយតែមួយ។

ចំពោះអ្នកមិនអាចធ្វើជាភ្នាក់ងារគណបក្សនយោបាយ **ឯកឧត្តម** បានបញ្ជាក់បន្ថែមថា សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ មេភូមិ ជំនួយការមេភូមិ និងកម្លាំងប្រដាប់អាវុធ មិនត្រូវបានអនុញ្ញាតឱ្យធ្វើភ្នាក់ងារគណបក្សនយោបាយសង្កេតមើលដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឡើយ។ **ឯកឧត្តម** បានជម្រាបជូនទៀតថា **គិតត្រឹមថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៤ នេះ គណបក្សប្រជាជនកម្ពុជា** បានធ្វើការផ្ទេរសិទ្ធិជូនតំណាងរបស់ខ្លួន ដើម្បីចុះហត្ថលេខាលើពាក្យសុំចុះឈ្មោះភ្នាក់ងារគណបក្សនយោបាយ (ទ.១០០៧) សម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតឆ្នាំ២០២៤។

អំពីសភាពការណ៍ទូទៅមុនចាប់ផ្ដើមដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត **ឯកឧត្តម ឌឹម សុវណ្ណារុំ** បានមានប្រសាសន៍ថា ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០២៤ នេះ ត្រូវបានរៀបចំនៅក្នុងសភាពការណ៍ដែលស្ថានភាពសង្គម សេដ្ឋកិច្ច និងនយោបាយនៅកម្ពុជាមានការវិវឌ្ឍល្អប្រសើរ នៅក្រោយការបោះឆ្នោតអសកល ចំនួន ២



អគារ គ.ជ.ប៖ វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ៖ 012 959 666 / 012 636 007 / 012 855 018
NEC Building : St. Ratsaphea, Sangkat Tonle Basac, Khan Chamkar Mon, Phnom Penh, Kingdom of Cambodia អ៊ីមែល៖ info@nec.gov.kh

គឺការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៥ និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ អាណត្តិទី៤ ពេលថ្មីៗកន្លងទៅ។ កត្តាសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សង្គមនេះហើយ ដែលធ្វើឱ្យ គ.ជ.ប មានលទ្ធភាពគ្រប់គ្រាន់ក្នុងការរៀបចំ ចាត់ចែង ដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតនាពេលខាងមុខនេះ។ ពិនិត្យជារួម ការងារមួយចំនួនយើងបានអនុវត្តរួចរាល់ហើយ ការងារមួយចំនួនទៀត យើងត្រៀមនឹងអនុវត្តជាបន្តបន្ទាប់ ដែលមានដូចជា៖

- ការរៀបចំបទបញ្ញា និងនីតិវិធី សម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ផែនការមេ ប្រតិទិនការងារ និងឯកសារគតិយុត្តផ្សេងទៀត សម្រាប់បម្រើឱ្យការចុះឈ្មោះបោះឆ្នោត
- ការបញ្ជាទិញសម្ភារ និងបរិក្ខារ សម្រាប់បម្រើឱ្យការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត
- ការរៀបចំវគ្គបណ្តុះបណ្តាល និងកិច្ចប្រជុំផ្សព្វផ្សាយជាមួយភាគីពាក់ព័ន្ធ អំពីការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០២៤ ទាំងនៅទីស្តីការ គ.ជ.ប នៅតាមលេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការបោះឆ្នោត និងនៅតាមឃុំ សង្កាត់
- ការស្រង់ស្ថិតិប៉ាន់ស្មានប្រជាពលរដ្ឋ និងការកំណត់ចំនួន និងទីតាំងការិយាល័យបោះឆ្នោត
- ការបោះពុម្ព និងចែកលិខិតអញ្ជើញជូនប្រជាពលរដ្ឋដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការ ឆ្នាំ២០២៣
- ការជ្រើសរើសសមាសភាពក្រុមចុះឈ្មោះបោះឆ្នោត ជាមន្ត្រីជាប់កិច្ចសន្យារយៈ-ពេលខ្លី ដើម្បីបម្រើការងារនៅតាមឃុំ សង្កាត់
- ការរៀបចំដឹកជញ្ជូនសម្ភារ និងបរិក្ខារ សម្រាប់បម្រើឱ្យការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត។

ឆ្លើយទៅនឹងសំណួររបស់ភាគីពាក់ព័ន្ធដែលចូលរួមក្នុងកិច្ចប្រជុំនោះ អំពីការគ្រោងលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត និងការចែកលិខិតអញ្ជើញដល់អ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោតចុងក្រោយ គ.ជ.ប បានបញ្ជាក់ជូនថា តួលេខ (៥៩.៩៦៨) ដែលគ្រោងលុបឈ្មោះ គ្រាន់តែជាការប៉ាន់ស្មាននៅឡើយទេ ការងារនេះ គឺថ្នាក់ឃុំ សង្កាត់ ជាអ្នកស្រង់ឈ្មោះអ្នកស្លាប់ អ្នកផ្លាស់ប្តូរទីលំនៅ រួចបញ្ជូនមក គ.ជ.ប តាមរយៈលេខាធិការដ្ឋានរាជធានី ខេត្តរៀបចំការ-បោះឆ្នោត ដើម្បី គ.ជ.ប ពិនិត្យ និងសម្រេច។ ចំពោះការចែកលិខិតអញ្ជើញអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោត គឺ គ.ជ.ប ចែកលិខិតអញ្ជើញនោះ តែអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការ ឆ្នាំ២០២៣ ដើម្បីឱ្យពួកគាត់មកពិនិត្យមើលឈ្មោះ និងទិន្នន័យរបស់គាត់ក្នុងបញ្ជីបោះឆ្នោតចុងក្រោយ។



អគារ គ.ជ.ប៖ វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ៖ 012 959 666 / 012 636 007 / 012 855 018
NEC Building : St. Ratsaphea, Sangkat Tonle Basac, Khan Chamkar Mon, Phnom Penh, Kingdom of Cambodia អ៊ីមែល៖ info@nec.gov.kh

រីឯអ្នកទើបគ្រប់អាយុ ១៨ឆ្នាំឡើងទៅ គិតដល់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៤ (អ្នកកើតមុន ឬកើតត្រឹមថ្ងៃទី១ ខែធ្នូ ឆ្នាំ២០០៦) គ.ជ.ប អំពាវនាវឱ្យពួកគាត់មកចុះឈ្មោះបោះឆ្នោត។

ជាចុងក្រោយក្នុងនាម គ.ជ.ប និងក្នុងនាម **ឯកឧត្តម ប្រាជ្ញ ចន្ទ** ប្រធាន គ.ជ.ប **ឯកឧត្តម ខឹម សុវណ្ណារ៉ុំ** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះតំណាងក្រសួង ស្ថាប័ន គណបក្សនយោបាយ សមាគម អង្គការមិនមែនរដ្ឋាភិបាល និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន ដែលបានចំណាយពេលវេលាដ៏មានតម្លៃអញ្ជើញចូលរួមក្នុងកិច្ចប្រជុំដ៏មានសារៈសំខាន់នេះ។ ឆ្លៀតក្នុងឱកាសនេះផងដែរ **ឯកឧត្តម** សង្ឃឹមជឿជាក់យ៉ាងមុតមាំថា តំណាងភាគីពាក់ព័ន្ធទាំងអស់ ពិសេសគ្រប់គណបក្សនយោបាយ សមាគម អង្គការមិនមែនរដ្ឋាភិបាល នឹងចូលរួមដាក់តំណាងរបស់ខ្លួន ដើម្បីសង្កេតមើលដំណើរការនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឆ្នាំ២០២៤ នេះ។ **ឯកឧត្តម** បានអំពាវនាវដល់ប្រជាពលរដ្ឋសូមអញ្ជើញទៅពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតឱ្យបានគ្រប់ៗគ្នា ចាប់ផ្តើមពី**ថ្ងៃទី១ ខែកញ្ញា រហូតដល់ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០២៤**។

ភាគីពាក់ព័ន្ធដែលចូលរួមក្នុងកិច្ចប្រជុំនោះ មានសមាសភាពមកពីតំណាងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អគ្គលេខាធិការដ្ឋានរដ្ឋសភា ក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ កងរាជអាវុធហត្ថលើផ្ទៃប្រទេស អគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា តំណាងគណបក្សនយោបាយ ចំនួន ៨ គណបក្ស តំណាងសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ចំនួន ១៦ ព្រមទាំងអ្នកសារព័ត៌មានសរុបចំនួនប្រមាណ ៥៨ នាក់៕



អគារ គ.ជ.ប ៖ វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ ៖ 012 959 666 / 012 636 007 / 012 855 018
NEC Building : St. Ratsaphea, Sangkat Tonle Basac, Khan Chamkar Mon, Phnom Penh, Kingdom of Cambodia អ៊ីមែល ៖ info@nec.gov.kh